ដៃម្នាក់ដែលនៅពីក្រោយគេហុចទូរសព្ទមកជ្រែកពួកអ្នកខាងមុខធ្វើឱ្យគ្នាវាងាកក្រោយទៅមើលម្ចាស់របស់មួយនេះព្រាត។

គេនោះហាក់ដឹងខ្លួនថាកំពុងរម្មូរពោះរឿងលុយម៉ឺនៗពេកបានជាកែទឹកមុខធ្វើជានិយាយបន្ទប់៖

«អញគ្រាន់តែចង់ដឹងថា វានេះកុហកបានយូរប៉ុនណា!»

Lorenzoប្រើម្រាមទាំងពីររបស់នាយចុចប៊ូតុង ក្រោមការលើកកាំភ្លើងមកភ្ជង់គ្រប់ទិសទី។ ការវេរលុយតាមបណ្ដាញមកកាន់លេខទូរសព្ទដោយប្រើប្រាស់ប្រព័ន្ធធនាគារជាច្រើនតង់មិនចាំបាច់ទៅកាន់បញ្ជរវេរលុយ ជារឿងដែលពួកគេមិនធ្លាប់ដឹងមកពីមុនទេ ប៉ុន្តែវាបានកើតឡើងពិតមែនក្នុងពេលនេះ។

ការទទួលសារជាអក្សរ បានលោតមកដល់ពេលដែលLorenzoងើបមុខហើយប្រគល់ទូរសព្ទមកឱ្យពួកគេវិញ។

ម្នាក់ៗចំហមាត់ពេលឃើញចំនួនទឹកប្រាក់លើសារមិនធ្លាប់បានទទួល។

«ពិតអត់! អានេះឆ្កួនភ្នែកយើង! វាសរសេរសារក្លែងក្លាយបោកយើង!»

ម្ចាស់ទូរសព្ទលាន់មាត់បែបនេះ ប៉ុន្តែភាពស្ងប់ស្ងែងកើតមានក្នុងកែវភ្នែករបស់គេ។ អាណិកជននិយាយតប៖

«អាចឱ្យលេខលើនេះទៅបងប្អូនទៅបើកលុយបាន!»

ពួកគេសម្លឹងមុខគ្នា។

ម្នាក់នៅពីមុខគេស៊ីញ៉ូឱ្យសញ្ញាគ្នាវា។ ឃើញដូច្នេះម្នាក់ដែលជាម្ចាស់ទូរសព្ទចាប់ផ្ដើមទាក់ទងចេញ។ អ្នកដែលនៅសល់សម្លឹងLorenzoពីលើចុះក្រោម ពីក្រោមឡើងទៅលើ។

«អ្ហែងគិតម៉េច បើអញបានលុយហើយនៅតែមិនលែងឯង?»

«ពួកឯងនឹងលែងបានការងារល្អៗ បានថ្លៃខ្ពស់ៗយកទៅធ្វើទៀត!»

ពេលដែលបុរសលែងខ្លាចលែងភ័យព្រោះតែអំណាចទឹកលុយរបស់គេ ជនទាំងក្រុមនេះកាន់តែច្រាស់ច្រាល់រារែកសម្លឹងមុខគ្នាមិនដាច់ស្រេច។

Lorenzoនិយាយបន្ថែម៖

«ក្រែងសព្វបែបយ៉ាងគ្រាន់តែដើម្បីលុយតើហ្អី? បើពួកឯងយកអាកន្ទាត់នោះធ្វើមេកោយបាន ម៉េចមិនព្រមទទួលយកអ្នកដែលចាយលុយធំជាងផង?»

«ឆ្ងឹយ! គ្មានអាណាម្នាក់ជាមេអញទាំងអស់មានលុយអញធ្វើ អត់លុយងាប់!»

ម្នាក់នៅពីចំហៀងនិយាយ ខាងឆ្វេងនិយាយទាំងងាកមុខដើរចេញ។ តែLorenzoដឹងថា គ្នាវាផ្សេងទៀត កំពុងតែត្រូដរដំណឹងលុយ។

«បើអ្អែងហ៊ានលេងប្អូនសន្លឹក ដឹងគ្នាហើយអាក្អួនអ្ហ៎!»

ម្នាក់នៅមុខគេនិយាយហើយ ថយទៅអង្គុយលើក្បាលឡាន។

Lorenzoដើរតាមគេនោះតត្រុក ព្រោះដឹងថាមានតែម្នាក់នោះទេ ងាយស្រួលនិយាយគ្នាជាងគេ ។ ឃើញអាណិកជនដើរមកតាម វានោះសម្លក់នាយហើយគំហកដាក់៖

«មិននៅឱ្យស្ងៀមមួយកន្លែង ក្រែងចុងកាំភ្លើងវាគ្មានភ្នែក!»

Lorenzoងាកសម្លឹងបីនាក់ទៀតដែលកំពុងប្រុងជើងការនៅឡើយ។ គេចាប់អារម្មណ៍ជាងគេតែតែកុងឡានដែលកន្លងមក រហូតដល់ពេលនេះមិនឮហើបមាត់អ្វីមួយម៉ាត់ណា។

គេសួរតិចៗទៅកាន់អ្នកដែលនៅលើក្បាលឡាន៖

«ខ្ញុំចង់ដឹងថាឡាននេះដាក់អីបានជាទូរសព្ទខ្ញុំខលមិនចេញ ហើយជំនួយការខ្ញុំជាអ្នកធ្វើ?»

ម្នាក់នោះនៅស្ងៀមបិទមាត់ដូចគេចុក។ អាណិកជនគួរតែដឹងថាការសម្ងាត់ជាក្បួនដ៏សំខាន់

នៃមុខរបររបស់ពួកគេ។ ពួកមនុស្សប្រភេទនេះបើមិនត្រូវជំនាញសួររបស់សមត្ថកិច្ចគឺមិនព្រមហើបមាត់ឆ្លើយនោះឡើយ កុំថាឡើយត្រឹមនាយជាមនុស្សមិនទាន់រួចពីស្លាប់១០០ភាគរយបែបនេះ។

«អាក្រម៉ាប់នោះ មានទំនាក់ទំនងជាមួយជំនួយការខ្ញុំ?»

គេសួរស្ទាបស្ទង់បន្ថែមក្នុងសូរសំឡេងទាបទំនងតែឮបានពីរនាក់ដឹងអីគូសន្ទនាតបវិញឮៗ ៖

«មើលអាម៉េចថាអាម្នាក់ហ្នឹងធាត់?»

Lorenzoងើបមុខមកវិញធ្វើឱ្យអ្នកដែលជ្រុលមាត់ហាក់ដឹងខ្លួនពីការឆ្លើយ។ យ៉ាងហោចណាស់អាណិកជនអាចចាប់ថ្នាក់បានជាស្រេចថា អ្នកដែលបញ្ជាពួកទាំងនេះពុំមែនជាមហាវីនទេ។

អ្នកនៅក្បាលឡានលូកដៃចង្អុលមុខនាយ ទាំងមួហ្មង ហើយពោលពាក្យទ្រគោះ៖

«ឈប់មាត់ប៉ប៉េះវ៉ី!»

ម្ចាស់ទូរសព្ទរត់ត្រឡប់មកវិញ។

Lorenzoដឹងពីលទ្ធផលជាមុនទៅហើយម្ល៉ោះហើយ នាយគ្មានអ្វីត្រូវភ្ញាក់ផ្អើលទេ។ ទោះបីជាយ៉ាងណា ពួកគេទាំងប្រាំរត់ទៅរកគ្នាហើយពិគ្រោះទាំងអំណរ។

ឆ្លៀតពេលនេះអាណិកជនរវេភ្នែកសម្លឹងមើលជុំវិញខ្លួន។

មេឃជិតងងឹតមែនទែនហើយ។

គេទើបនឹងចាប់អារម្មណ៍ថាទីនេះត្រជាក់ទៅៗ។ វាមិនទំនងថានៅក្បែរភូមិករទេ គួរតែនៅក្បែរព្រៃ។

មនុស្សម្នាក់វិលមកវិញជាមួយទឹកមុខស្រស់ស្រាយទោះជាមិនមានស្នាមញញឹម។

«ទៅបាន! តែទៅឱ្យឆ្ងាយប្រយ័ត្នគេរកឃើញ!»

គេឆ្លៀតនិយាយភ្លាមៈ

«ឯងមិនទាន់ប្រាប់ខ្ញុំទេ ថាអ្នកបញ្ជាឈ្មោះអី!»

«កុំរញ៉េរញ៉ៃច្រើន!»

គេនោះគំហកខ្លីហើយលូកដក កាំភ្លើងខ្លីមួយពីចង្កេះខោហុចមកឱ្យ។

«អំណោយហ្វ្រី! ជួបគ្នាលើកក្រោយកុំភ្លេចឱ្យលុយចាយ!»

វាជាកាំភ្លើងដ៏ចាស់មួយតែធ្ងន់កណ្តុក។

អាណិកជនទទួលមកកាន់ទាំងរងើរងើ។

«តោះកុំនៅយូរ!»

ពួកគេមានសភាពដូចជាបានលុយហើយខ្លាចមានគេមកទាន់ ម្នាក់ប្រញាប់ទៅតែម្នាក់ទៀតស្ទុះចូលមកស្ទាបហោប៉ៅនាយរាវរកសព្វបែបយ៉ាងប្រមូលយកទៅអស់មិនសល់សូម្បីតែកន្សែងជូតសម្បោរ។

ពួកវាកេះគ្នាបម្រុងចាកចេញ តែអាណិកជននៅតែមិនអស់ចិត្ត។

គេក៏ចាំបាច់ថែរក្សាអាយុជីវិតជាមុនសិនដែរ បានជាទាញដៃម្នាក់ក្រោយគេនោះមកវិញហើយអង្វរៈ

«សុំទូរសព្ទវិញមក! ខ្ញុំមិនស្គាល់ផ្លូវទេ!»

«កុំនៅញ៉ិមញ៉ុមទៅខាងត្បូងនោះទៅ! រត់ឱ្យឆ្ងាយទៅ! ផ្លូវនោះឧស្សាហ៍មានគេចេញចូលច្រើន!»

មិនថាមានអ្វីកើតឡើងនោះទេ គេដឹងថា ពួកនេះមិនព្រមឱ្យគេវិលចូលទៅក្នុងឡានយករបស់ឡើយ។

គ្រោះថ្នាក់នៅតែស្រមោលអន្ទោលតាមប្រាណ ព្រោះថាឯកសារសំខាន់នៅទីនោះទាំងអស់។

ស្នូររថយន្តបោលមកពីចម្ងាយ ។

ពួកគេទាំងប្រាំវិលមកក្នុងសភាពប្រុងជើងការវិញ។ អ្វីដែលអាណិកជនទើបនឹងរួចជីវិតត្រូវធ្វើក្នុងពេលនេះគឺដកថយទៅតាមទិសដែលគេចង្អុលប្រាប់។

គេដើរបណ្ដើររត់បណ្ដើរក្រោមផ្សែងស្រអាប់ងងឹតទៅៗ....

ដើរសឹងរលេះជើងហើយនៅតែគ្មានឃើញស្រមោលកង់មួយកុំថាឡើយម៉ូតូ។

«ពួកនេះមានចេតនាបញ្ឆោតយើងឱ្យទៅដេកដាច់ពោះក្នុងព្រៃ?»

គេគិតទាំងទោមនស្ស គិតហើយគិតទៀតពីជោគវាសនាចំពោះមុខ និងសមាសភាពអ្នកដែលបង្កបញ្ហានេះឡើងចំពោះគេ។

ស្នូរគ្រាប់កាំភ្លើងលាន់មករប៉េះរប៉ោះ.....

វាជាការដាស់អារម្មណ៍ប្រកបដោយប្រសិទ្ធភាពថា ពួកមនុស្សទាំងប្រាំទំនងជាពើបប្រទះនឹងអ្នកដែលទើបមកដល់ហើយឆាកប្រយុទ្ធបានកើតមាន?

មិនថារឿងហេតុរបៀបណាទេ គេចាប់ផ្ដើមបង្កើនល្បឿនរត់។ មិនបានប៉ុន្មានផង រាងកាយបុរសសង្ហា ដែលមិនថ្នឹកនឹងការរត់កាត់ភាពងងឹតបានភ្លាត់ជំហរដួលទៅលើដី។ ចៃដន្យទីនេះពុំមែនជាដីរាបស្មើម៉្លោះហើយប្រុសស្អាតចាប់ផ្ដើមរមៀលធ្លាក់ដោយមិនដឹងទិសដៅ។

«បន្ទាប់ពីរមៀលធ្លាក់នោះហើយ ទើបបងមានសំណាងបានជួបអូន!»

គេនិយាយតិចៗធ្វើឱ្យនាងដកអារម្មណ៍ចេញពីរឿងអតីតបាន។

សេចក្ដីភ្ញាក់ផ្អើលនិងភ័យបារម្ភ រំជួលចិត្តពេញបេះដូងនៅមិនស្មើនឹងចិត្តស្នេហាដែលបានជាមានចំពោះនាយជ្រៅសន្ធឹមទៅហើយ។ នាងនៅស្ងៀមត្រកងបាច់បុប្ផា និងស្ថិតក្នុងរង្វង់ដៃនាយ ។

«មិនសួរនាំបងខ្លះទេពេលដឹងការពិតអស់ហើយ!»

គេនិយាយតិចៗក្បែរត្រចៀកនាង ចំណែកដង្ហើមពួកគេសឹងតែប្រែរួមជាមនុស្សតែមួយបាន។

ស្រីស្អាតគិតបន្តិចទើបនិយាយយឺតៗ៖

«ចង់សួរច្រើនណាស់ តែគិតហើយក៏ខ្ជិលសួរវិញ!»

«ហេតុអី!»

«ព្រោះ! អូយខ្ជិលនិយាយណាស់!»

«ម៉េចក៏ស្រាប់តែក្លាយជាខ្ជិលអីខ្ជិលម៉េះ?!»

«ហ្មែនឯណា! គ្រាន់តែមិនចង់ឱ្យអ្នកខ្លះ ទើសទាល់ចិត្តពិបាកឆ្លើយ!»

ប្រុសស្អាតញញឹមដាក់ មាត់នាយក្បែរថ្ពាល់នាង គេខ្សឹប៖

«សម្រាប់កូននាគតូចរបស់បង សំណួរអ្វីក៏បងនឹងឆ្លើយសម្រាប់អូនទាំងអស់!»

«ចុះបងដែលចាប់មនុស្សស្រីកើតឆ្នាំ២០០០ទាំង៣៥នាក់នោះដែរ?!»

«Lorenzoមិនដែលធ្វើអំពើខុសច្បាប់ទេ!»

គេឆ្លើយលឿនយ៉ាងនេះ ចិត្តនាងក៏ឆាប់ធូរទ្រូងខ្យាកពីក្ដីបារម្ភណែនពេញក្នុងទ្រូងបានក្នុងពេលទន្ទឹមគ្នា។

ស្រីស្អាតងក់ក្បាលផ្ទក់ៗជាសញ្ញាថានាងព្រមជឿហើយនិងយល់បានច្បាស់គ្រប់សព្វបែបយ៉ាងថាបុរសនេះបានលង់ក្រោមល្បិចមនុស្សអាក្រក់  ក៏ជាសន្និវាសដែលចារឱ្យគេមកជួបនឹងនាង។

ស្នេហាមួយនេះហាក់បីដូចជាភព្វនិស្ស័យព្រឹទ្ធិព្រេងមួយ ដែលធ្វើឱ្យតូចនារីមានអារម្មណ៍ថាខ្លួនជាមនុស្សស្រីដែលមានសំណាងបំផុត។

«ហើយចុះ មិនសួររឿងផ្សេងទៀត?!»

Lorenzo និយាយបន្ថែមទាំងសម្លឹងផ្ដោតសរសៃសក់នាងរេរាំតាមកម្លាំងខ្យល់មកលើទ្រូងនាយ។

«ខ្ចិលណាស់ !ទោះបងជាអ្នកណា ជំនិតវិរៈ ពូវ៉េង ឬក៏តារាសប្បុរសLorenzoវាដូចតែគ្នាទាំងអស់ហ្នឹង! ការស្រលាញ់នេះ គ្មានថ្ងៃផ្លាស់ប្តូរទេ!»

គេញញឹមតិចៗហើយបន្ទរៈ

«ត្រូវហើយ! មនុស្សប្រុសម្នាក់នេះ កើតមកសម្រាប់ស្រលាញ់អូន! ទោះវាក្លាយជាអ្វីក៏នៅតែស្រលាញ់សន្យាជានិច្ច! »

គេបង្អង់បន្តិចទើបនិយាយបន្តៈ

«មួយទៀត!....»

អ្វីម្យ៉ាងបានបណ្តាលឱ្យគេកើតនឹកឃើញឡើងមកវិញ ហើយលេចចេញនូវចិត្តភ័យព្រួយជាសម្ងាត់ប្រែសកម្មភាពទៅជា ស្ងាត់ស្ងៀម គាំងអណ្តាតលែងហារស្តីកណ្តាលទី ។ មនុស្សជាច្រើនដែលនៅជុំវិញគេ ហើយដែលមានចិត្តស្មោះ ស្រលាញ់ថ្នាក់ថ្នមគេ ឈឺឆ្អាលចំពោះគេ រមែងតែងតែរងទុក្ខវេទនា រហូតគេលែងចង់នៅក្បែរអ្នកណាទាំងអស់?

តរុណី នៅរង់ចាំយ៉ាងអន្ទះសា ប៉ុន្តែមិនឮសង្សារបន្ទរអ្វីថែម  ទើបដាច់ចិត្តងើបមុខសួរៈ

«អីទៅ?!»

បុរសនេះដៀងភ្នែកមកសម្លឹងមនុស្សស្រីដែលជាតិនេះគេលែងចង់សម្លឹងមនុស្សស្រីណាក្រៅពីនាង ។

នារីនេះ ទាំងក្មេងសេចក្តី ទាំងបរិសុទ្ធចិត្តកាយ ទាំងមិនរវល់នឹងសង្គមធំនៅទីក្រុង ប្រុសណាឃើញហើយ បើមិនលង់ចិត្តចង់ប្រើជីវិតដែលនៅសល់ជាមួយនាង មានតែគេនោះជាមនុស្សល្ងង់។

នរៈលាដៃទាញសន្សាមកបំបែររកទ្រូង ហើយផ្ទឹបច្រមុះគេលើថ្ងាសស្រីស្អាត ថើបនាងថើៗ ថ្នមៗ។

ដង្ហើមគេបានជាគេបណ្តុះជាសំនៀងសម្ងាត់នៃជម្រៅបេះដូងមនុស្សពីរនាក់ប្រើភាសាតែមួយ។ ពេលវេលាកន្លងទៅ ដោយមិនមានសម្តីអ្វី ចេញពីមាត់តែនាងក៏លែងសួរព្រោះ ភាសាចិត្តថ្លើមបន្សល់បានច្បាស់ជាងអ្វីគ្រប់យ៉ាងទាំងអស់ ។

ស្រាប់តែ.....

«មិនថា ថ្ងៃក្រោយមានរឿងអ្វីមិនល្អកើតឡើង បងសូមស្បថ ទទួលយកវាជំនួសអូន!»

នាងងើបមុខសម្លឹងគេទាំងរលីងរលោង។

សេចក្តីស្រលាញ់នៃបុរសខ្វាត់ភ្លាត់ បានធ្វើឱ្យនារីទៅជាភាន់ភាំងមិនដឹងតបស្នងគេបែបណាឱ្យល្អ តែភ្នែកបួនជំពាក់គ្នា ពិតជាធ្វើឱ្យនាងទ្រាំមិនបានក្នុងការតបសងចិត្តដ៏មហិមារបស់គេ។

នាងលោទៅថើបថ្ពាល់គេ ធ្វើឱ្យអ្នកភាន់ភាំងបន្ទាប់គឺជានាយវិញ។

បុរសនេះស្មានយ៉ាងណាក៏មិនគិតថា នាងនឹងថើបខ្លួនកណ្តាលវាលទាំងមិនចេញស្តីទាំងមិនឱ្យសញ្ញាអ្វីបែបនេះឡើយ។

នាងនៅស្ងៀម ស្ទើរញញឹមស្ទើរអៀនប្រៀនសម្លឹងមុខបុរសម្ចាស់ចិត្ត ហាក់ចង់ប្រាប់ថា ឈប់និយាយទៅ អូនជឿបងគ្រប់យ៉ាង។

បុរសពិតជាឈប់និយាយ តែគេឱនមកហើយស្វាគមន៍បបូរមាត់ស្រីតូចនូវអនុស្សាវរដ៏មានអត្ថន័យជាងអ្វីគ្រប់យ៉ាងលើលោក។

**ទឹកភ្នែកលើអគ្គី**

សន្យា ស្រក់ទឹកភ្នែកតក់ៗ មកលើបាច់ផ្កាក្រៀមស្រពោនដែលបានបន្សល់ទុកនិងរលកអនុស្សាវរីយ៍ចាស់ដែលនាងយល់ថាគួរតែបញ្ចប់វាត្រឹមថ្ងៃនេះ។

មិនថា ចិត្តស្រលាញ់មួយនេះ តពីបុរាណមករាប់ទសវត្ស ជាទម្រង់នៃមនោសញ្ចេតនាពិត ឬគ្រាន់តែជាការទាក់ចិត្តម្តងៗរបស់ថ្លៃ  មិនថា ពេលវេលាទាំងឡាយដែលបងចូលមក ជារឿងនិទានសម្រាប់លម្អជីវិតមួយពេល  ឬជាការពិតដ៏ឈឺផ្សារៀងរហូត តែអូនមិនដែលស្តាយក្រោយឡើយ។

នៅជិតបង្កើយ តែដូចឆ្ងាយហួសជើងមេឃ នៅឆ្ងាយគ្នាអនេក តែបេះដូងអូននៅលោតហៅឈ្មោះរាម រឿងនិទាននៃស្នេហាក្បែរជើងភ្នំ ទោះក្លាយជារឿងព្រេងចំណេរពាន់ឆ្នាំក្រោយ អូននៅតែចាត់ទុកវាជាស្នេហាដ៏មានតម្លៃមួយទាំងដែលរាងកាយទាំងពីរអស់សិទ្ធិស្និទ្ធស្នាល។

សន្យជូតទឹកភ្នែក ។

នាងកេះភ្លើង ហើយដុតកម្ទេចវត្ថុចុងក្រោយ ជាមួយទឹកភ្នែកស្រក់កំដរអំណាចព្រះអគ្គី។

បបូរមាត់ក្រៀមក្រំ ខានញញឹមជាយូរណាស់មកហើយ ពេលនេះហើបនិយាយខ្សឹបខ្សៀវ ទៅកាន់វាដូចជាផ្កាស្រពោននេះកំពុងតែមានវិញ្ញាណពិតៗ៖

«មិនថា ថ្ងៃក្រោយមានរឿងអ្វីមិនល្អកើតឡើង អូនសូមស្បថ មិនឱ្យបងរងវាជំនួសអូនទេ! អូនអាចទ្រាំបានគ្រប់សព្វបែបយ៉ាងដើម្បីបង! សន្យាមិនបានស្អប់ ក៏មិនបានខឹង! ប៉ុន្តែជួនកាល មនុស្សយើង ត្រូវរៀនទទួលយកការពិត ហើយបំភ្លេចរឿងអតីតកាលពិតមែន! ប្រសិនស្រីម្នាក់នេះ មានវាសនាត្រឹមតែជាស្នេហាមួយគ្រាក្នុងជីវិតថ្លៃ អូនក៏មិនមានអាក់អន់អ្វី មានតែសូមឱ្យរៀមមានជីវិតតទៅមុខល្អជាងនេះ!លាហើយLorenរបស់អូន!លាស្នាមថើប និងស្នេហាដែលយើងផ្លាស់ប្តូរចំពោះគ្នា! បងជាអនុស្សាវរីយ៍ដ៏ល្អបំផុតក្នុងជីវិតរបស់អូន!»

**សំណាងបេះដូង**

«លោកប្រុស! អ្នកនាងពិនណាមកដល់បាងកកហើយ! ឥឡូវកំពុងនៅបន្ទប់រង់ចាំ!»

Lorenzអង្គុយលើរទេះអ្នកជំងឺ។

ភ្នែកគេសម្លឹងលំហមេឃ ដោយស្ងប់ស្ងាត់ បែរខ្នងមករកគូសន្ទនា ទាំងមិនមានប្រតិកម្មអ្វីចំពោះសម្តីវឌ្ឍនៈឡើយ។

បណ្តោយឱ្យពេលវេលាកន្លងទៅបន្តិចទើប វឌ្ឍនៈដែលបង្អស់រង់ចាំអស់មួយខណៈដាច់ចិត្តបញ្ចេញយោបល់ជួយចៅហ្វាយ៖

«ចាំខ្ញុំរកវិធីឱ្យនាងវិលទៅស្រុកខ្មែរវិញ!»

Lorenzonវាដៃឃាត់៖

«ឱ្យពិនណាចូលមក!»

Lorenzoធ្លាប់បដិសេធមនុស្សស្រីដែលខ្លួនគេស្រលាញ់ដល់ទៅ១៤លើកទៅហើយ ក្នុងអំឡុងពេលដែលគេរស់កំដរវាងកាយមិនស្គាល់ខ្លួនឯងថាជាអ្នកណា ពេលនេះ ដឹងខ្លួនពីអតីតមកវិញហើយ គេមិនចង់ គេចវេះអ្វី មិនចង់អូសបន្លាយអ្វីបន្តទៅទៀតឡើយ។

គេរុញខ្លួនឯងបំបែរទៅរកមាត់ទ្វារ។

វិនាទីនីមួយៗរំលងទៅ នាំជាមួយនូវទស្សនៈមួយចំនួនក្នុងបេះដូងគេ.....ជីវិតមនុស្សយើងមិនមែនជាទីដែលសម្រាប់ចំណាយលើការស្អប់ខ្ពើមគុំកួនចងអាឃាតឬ ថ្កោលទោសវាយប្រហារអ្នកណាទាំងអស់ព្រោះយើងគ្មានពេលច្រើនទេ។ មនុស្សដែលយើងស្រលាញ់ និងមនុស្សដែលស្រលាញ់យើងកំពុងរង់ចាំយើងយ៉ាងអន្ទះសា មិនថា យើងក្លាយទៅជាយ៉ាងណា យើងនៅតែមានតម្លៃជានិច្ច

ចំពោះគេ។  មិនថា យើងក្លាយទៅជាអស្ចារ្យបែបណា យើងនៅតែគ្មានន័យដដែលសម្រាប់មនុស្ស ដែលមិនខ្វល់ពីយើង។

ពិនណាបង្ហាញខ្លួនទាំងក្រៀមក្រំ។ ភ្នែកនាងក្រហមដូចទើបនឹងយំរួច។

បេះដូងប្រុសម្នាក់នេះ មិនបានរវល់នឹងគិតថាតើអភិជនរូបនេះសម្ដែងល្ខោនឬមួយក៏នាងយំអាណិត នាយពិតៗឡើយ។

នៅពេលមួយដែលមនុស្សយើងរកឃើញទីសំចតច្បាស់ មានគោលដៅផ្ទាល់ខ្លួនរួចរាល់ហើយ គេ មិនចំណាយពេលអ្វីទៅលើការតាមដានអ្នកផ្សេងថាគិតយ៉ាងណាចំពោះខ្លួន មានចេតនាចំពោះខ្លួន ទៀតនោះឡើយ។

«ហេតុអីបងធ្វើអ៊ីចឹងកើត!មកលួចវះកាត់មិនឱ្យអូនដឹង?!»

នាងនិយាយខ្សឹកខ្សួលចំណែកនាយមិនបានបង្ហាញទឹកមុខថាខឹង ឬជាអ្វីទាំងអស់។ គេនៅស្ងៀមឱ្យ នាងមានប្រតិកម្ម អស់ចិត្តទើបនិយាយ៖

«បងមិនអីទេពិនណា!»

«យើងជិតរៀបការហើយ!»

នាងបន្ទោសតិចៗទាំងលូកដៃមកក្ដោបលើប្រអប់ដៃនាយ។

បុរសឆ្លៀតពេលដកដៃចេញពីនាងស្រាលៗ។

ប៉ះពាល់នាង គេគ្មានអារម្មណ៍អ្វីក្រៅតែពីនឹកឃើញដល់កូននាគតូច។ ចិត្តថ្លើមគេផ្ញើនៅផ្ទះអនាគត ទៅហើយ។ តទៅគ្មានការប៉ះពាល់ណាមួយរបស់ស្រីផ្សេងដែលអាចរំញោចដល់បេះដូងប្រុសម្នាក់ នេះទៀតនោះទេ។

គេវាចាតិចៗតបទៅនឹងកែវភ្នែកសង្ស័យរបស់នាង៖

«មង្គលការយើងមិនអាចកើតឡើងបានទេ!»

នាងស្លន់ស្លោ ហើយជូតទឹកភ្នែកយ៉ាងញាប់។ ចិត្តបុរសមិនបានខូចខាតអ្វីជាមួយភាពសោយសោកា របស់នាង គេរឹតតែមិនគិតថាបានធ្វើអ្វីមួយខុសចំពោះនាងឡើយ។

«        Lorenzoបងមិនអាចធ្វើរបៀបនេះដាក់ពិនណាបានដាច់ខាត!»

Loren តបតស្រោលទៅនឹងកែវភ្នែកខឹងសម្បាររបស់នាង៖

«មនុស្សមិនបានស្រលាញ់គ្នា ! អាពាហ៍ពិពាហ៍ មិនមែនរឿងលេងសើចទេ! បងរកឃើញ អតីតកាល វិញហើយ បងដឹងថាយើងមិនអាចលួតលាស់អ្វីលើសពីនេះទាំងអស់»

នាងស្រែកទាំងទឹកភ្នែក៖

«ហើយបងឯងនឹងអាលទៅរៀបការជាមួយនាងសំរ៉ៃ សន្យាហ្នឹងមែនដែរអត់? គិតថាសមគ្នាណាស់ទៅ?!»

«ចុះពិនណាគិតថា ខ្លួនសមជាកូនក្រមុំរបស់ប្រុសពិការម្នាក់ដែរ? គ្រួសារនាងទទួលយកភាពជាមនុស្សប្រុសដែលមិនចំជាប្រុស និងពិការភាពរបស់ថៅហ្វាយខ្ញុំបានដែរ?!»

នេះគឺសំឡេងវឌ្ឍនៈ ដែលលាន់ស្នូរមកពីក្រោយខ្នងនាងធ្វើឱ្យពិនណាញ័រដៃ។

ទាំងពាក្យពិការ និងទាំងវត្តមានជំនួយការម្នាក់នេះធ្វើឱ្យនាងស្លន់ចិត្ត។

៦ឆ្នាំហើយ ដែលនាងខំរកគ្រប់មធ្យោបាយ លាក់កំបាំងអតីតកាលរបស់ប្រុសស្អាត ។ ចុងក្រោយគេបានមនុស្សជំនិតមកនៅក្បែរវិញ ?

នាងបែរមករកវឌ្ឍនៈ។

នាយជំនួយការសម្លឹងនាងដោយក្រៀមក្រំ ធ្វើឱ្យពិនណានឹកឃើញភ្លាមដល់រឿងដែលសំខាន់ជាងនេះ មួយគឺអនាគតមនុស្សដែលនាងចង់បានមកជាស្វាមី។

នាងបែរយឺតៗត្រឡប់មកវិញ រួចសម្លឹង Lorenzoតាំងពីក្បាលដល់ចុងជើង។

គេនេះពិការហើយ?

គេលែងជាមនុស្សប្រុសពេញលក្ខណៈម្នាក់ថែមទាំងកម្រើកដៃជើងដើរមិនបានផង តើស្រីណាយកអនាគតទៅប្តូរជាមួយទៅ?

នាងគ្រវីក្បាលហើយស្រែកទ្រហោយំ។

«បងឯងរឹងរូសណាស់ Lorenzo! ចង់បានអតីតកាលហ្នឹងមកវិញធ្វើស្អីទៅអ្ហា?!បានអីមកវិញ?ឥឡូវនៅលើកៅអីរុញមួយជីវិត បងឯងពេញចិត្តណាស់មែនទេ?!»

Lorenzoនៅស្ងៀម កំដរភាពខូចចិត្តរបស់នាង ។

ពិនណាចាកចេញទៅវិញ ហើយគេមិនដែលឃើញនាងត្រឡប់មកសួរសុខទុក្ខនាយម្ដងណាទៀតឡើយ។ Lorenzoមិនបានខកចិត្តមិនបានសោកស្ដាយអ្វីទាំងអស់ ព្រោះគេដឹងថា អ្វីទៅដែលខ្លួនគេពិតជាត្រូវការពីសេចក្ដីស្រលាញ់។

សេចក្ដីស្រឡាញ់ តាមពិតគឺជាជីវិតរបស់មនុស្សគ្រប់គ្នា។ មនុស្សអាក្រក់ល្អរមែងតែងចង់កើតឡើងពីក្ដីស្រលាញ់ រស់នៅមានក្ដីស្រលាញ់ និងស្លាប់ទៅជាមួយចិត្តស្រលាញ់។

ដៃគូជីវិតរបស់ Lorenzoមិនមែនជាដៃគូជំនួញ ដៃគូសមឋានៈ ដៃគូឱ្យសង្គមមើលឃើញកោតសរសើរស្ញប់ស្ញែងទេ គេជាជំពូកមនុស្សដែលចង់មាន នរណាម្នាក់ជាពិសេសមកបំពេញបន្ថែមភាពខ្វះខាតនៃជីវិត មកចែករំលែកភាពទុក្ខព្រួយ សោមនស្ស សប្បាយ និងបង្កើតអនុស្សាវរីយ៍នៃការរស់នៅរួមជាមួយគេ ដោយមិនចាំបាច់មានលក្ខខណ្ឌ មិនចាំបាច់ ផ្លាស់ប្ដូរបុគ្គលិកលក្ខណៈមិនចាំបាច់គិតអំពីសកម្មភាពផ្គាប់ផ្គុនតណ្ហាឬបង្អួតសម្ញែងចិត្តអ្នកដទៃគេដឹងថា គេមានស្នេហាដ៏ត្រឹមត្រូវមួយសម្រាប់ជីវិតខ្លួន ក្នុងការធ្វើជាខ្លួនឯងដ៏ល្អបំផុត និងរស់នៅតទៅជាមួយមនុស្សស្រីម្នាក់ដែលមិនថាគេក្លាយទៅជាអ្វីក៏នាងមិនព្រមបោះបង់។

ទំនាក់ទំនងជាវសៀវភៅនេះ ០១៥២១៣១១១